00367763

**Declassified to Public**

**12 April 2013**

D130/10/1

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 27 / 08 / 2009
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. Fuy

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ ២៧)

**ភាគីអ្នកតម្កល់៖** ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន

**ដាក់តម្កល់ជូន៖** អង្គបុរេជំនុំជម្រះ

**ភាសាដើម៖** ភាសាបារាំង

**កាលបរិច្ឆេទដាក់ឯកសារ៖** ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើឡើងដោយភាគីអ្នកតម្កល់៖ សាធារណៈ

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យឡើងវិញនូវចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងបណ្ណសារ៖

ហត្ថលេខា៖

**ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 28 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA. Fuy

---

# បណ្ដឹងឧទ្ធរណ៍របស់លោកខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម

---

**បញ្ជូនដោយ៖**

**សហមេធាវីរបស់លោក ខៀវ សំផន**

មេធាវី ស សុវាន

មេធាវី Jacques VERGÈS

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

លោក Uldis KRASTINS

**បញ្ជូនទៅ៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ផុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និង ដើមបណ្ដឹងរដ្ឋប្បវេណី**

00367764

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស/(អ.ប.ជ 27)

## ជូនចំពោះអង្គបុរេជំនុំជម្រះ

**ម្យ៉ាង ដោយយល់ឃើញថា៖**

- ការហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ដែលចែងដោយច្បាប់ដែលអាចយកមកអនុវត្តបាន និងជាអាទិ៍:
    - ❖ **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ចែងថា៖ "ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី *មិនត្រូវចាត់ទុក* ជាភស្តុតាងនៃពិរុទ្ធភាពទេ"។
    - ❖ **មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និង ទោសផ្សេងទៀត ឬ ការប្រព្រឹត្តិដោយឃោឃៅ ដោយអមនុស្សធម៌ ឬ ដោយថោកទាប** ចែងថា៖ "គ្រប់រដ្ឋភាគីត្រូវធានាថា រាល់ចម្លើយសារភាពណាដែលគេជឿជាក់ថាទទួលបានតាមរយៈការធ្វើទារុណកម្ម មិនអាចលើកយកមកសម្អាងជាមូលដ្ឋានភស្តុតាងនៅក្នុងនីតិវិធីបានទេ លើកលែងតែក្នុងករណីដែលចង់បង្ហាញថាមានការសួរយកចម្លើយសារភាពដើម្បីប្រឆាំងនឹងជនត្រូវចោទពីបទប្រព្រឹត្តទារុណកម្មប៉ុណ្ណោះ។"
- លក្ខណៈច្បាស់លាស់នៃបទបញ្ញត្តិទាំងនេះ តម្លៃនៃបទបញ្ញត្តិនៅក្នុងឋានានុក្រមនៃបទដ្ឋាន និងអានុភាពនៃបទបញ្ញត្តិនៅក្នុងប្រព័ន្ធគតិយុត្ត។
- ការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម ដែលជាបទដ្ឋាន *us Cogens* ដែលការគាំទ្រការហាមឃាត់នេះគឺជាកម្មវត្ថុនៃការជជែកពិភាក្សា។
- គោលការណ៍នៃបំណកស្រាយដ៏ម៉ត់ចត់ត្រឹមត្រូវនៃច្បាប់ព្រហ្មទណ្ឌ គោលការណ៍នៃការបែងចែកដាច់ពីគ្នានូវអំណាចនិងភាពចាំបាច់ក្នុងការការពារយុត្តិធម៌ សណ្តាប់ធ្នាប់សាធារណៈ និង ផលប្រយោជន៍ទូទៅ។

**ម្យ៉ាងទៀត ដោយយល់ឃើញថា៖**

00367765



- ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម[1] ដែលទទួលអញ្ញត្តិស្របច្បាប់ (ដែលធ្វើឱ្យគេកត់សម្គាល់ដោយស្របច្បាប់) និងអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលមានចែងដោយការហាមឃាត់ សម្រាប់គោលដៅដែលត្រូវបានផាត់ចោលយ៉ាងជាក់ស្តែងនិងយ៉ាងច្បាស់លាស់ដោយច្បាប់ នៅក្នុងកម្រិតនៃប្រព័ន្ធយុត្តិធម៌។

**សហមេធាវីការពារក្តីយល់ឃើញថា៖**

1. ដោយធ្វើការបកស្រាយអញ្ញត្រកម្មដែលចែងដោយអត្ថបទច្បាប់ ថាមិនមែនជាមធ្យោបាយក្នុងការបង្កើតនូវអង្គហេតុពិសេសមួយ ("ចម្លើយសារភាពមួយត្រូវបានធ្វើឡើង) ប៉ុន្តែដើម្បីបញ្ជាក់និងទទួលយកទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនម្នាក់ ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលគេចោទប្រកាន់ខ្លួន ដោយយកលេសថាខ្លួនជា "អ្នកធ្វើទារុណកម្មប្រកបដោយសក្តានុពល"[2]។ សហចៅក្រមស៊ើបអង្កេតបានរំលោភច្បាប់ បានធ្វើជ្រុលហួសពីអំណាចរបស់ខ្លួន និងបានធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់ស្មារតីនៃយុត្តិធម៌។
2. ដោយលើកទឹកចិត្ត បញ្ជាក់ថាត្រឹមត្រូវ និងគាំទ្រនូវដំណើរការមួយបែបនេះ សហព្រះរាជអាជ្ញាដោយស្ថិតនៅឆ្ងាយពីការការពារផលប្រយោជន៍ដែលខ្លួនអះអាងថាត្រូវការពារ បានធ្វេសប្រហែសចំពោះករណីកិច្ចរបស់ខ្លួនក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ និង ការការពារផលប្រយោជន៍ទូទៅ។
3. ហើយទីបំផុត ប្រសិនបើវិធានផ្ទៃក្នុងមិនបានចែងដោយឱ្យបានច្បាស់លាស់អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណាមួយ គឺគ្រាន់តែដោយហេតុថាដីកានេះមិនដែលកើតមានទាល់តែសោះ ហើយសេចក្តីសម្រេចនេះគឺជាការខូចកិត្តិយសដល់យុត្តិធម៌កម្ពុជានិងអន្តរជាតិ ហើយវាជាករណីកិច្ចដាច់ខាតសម្រាប់ចៅក្រមនៃអង្គបុរេជំនុំជម្រះដើម្បីទទួលយកបណ្តឹងឧទ្ធរណ៍នោះ។

---

[1]ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ *ឯកសារតុលាការ D130/8*

[2] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ *ឯកសារតុលាការ D130/8* កថាខណ្ឌទី២៤

00367766



4. ជាការពិត គ្រោះថ្នាក់និងកំហុសនៃសេចក្ដីសម្រេចណាមួយសម្រាប់យុត្តិធម៌និងកេរ្ដិ៍ឈ្មោះរបស់ចៅក្រម គឺមានលក្ខណៈធំធេង។ ហើយក្រុមការពារក្ដីចង់លើកចំណុចទាំងនេះធ្វើជាភស្ដុតាង៖

**➢សេចក្ដីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតដោយយោងលើដីកាសម្រេចលើការប្រើប្រាស់ភស្ដុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម៖**

“ (...) ត្រឹមដំណាក់កាលនេះ យើងអាចត្រឹមតែធ្វើការអះអាងថា មិនមានព័ត៌មានណាមួយដែលបានបង្ហាញពីការពិតនៅក្នុងចម្លើយសារភាពទាំងនោះនៅឡើយទេ។ ការវាយតម្លៃអំពីភាពដែលអាចគួរឱ្យជឿជាក់បានអាចធ្វើទៅបាន បន្ទាប់ពីការបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ គឺនៅពេលដែលសំណុំរឿងពេញលេញគ្រប់គ្រាន់។ ដូចគ្នានឹងភស្ដុតាងទាំងអស់ដែលមានក្នុងសំណុំរឿងដែរ ភាពដែលអាចគួរឱ្យជឿជាក់បាននៃចម្លើយសារភាព នឹងត្រូវបានគេវាយតម្លៃមួយករណីម្ដងៗ។ សូមបញ្ជាក់ផងដែរថាដោយយោងលើប្រភេទនៃភស្ដុតាងទាំងនេះ និងមធ្យោបាយដែលវាទទួលបាន សហចៅក្រមស៊ើបអង្កេតនឹងពិចារណាយកឯកសារទាំងនេះមកធ្វើជាភស្ដុតាងដោយភាពប្រយ័ត្នប្រយែងបំផុត”[3]។

**➢សេចក្ដីប្រកាសរបស់លោក កាំង ហ្កេកអៀវ ហៅ ឌុច ស្ដីពីការប្រើប្រាស់ចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ៖**

“សំណួរ: តើបក្សកុម្មុយនិស្ដកម្ពុជាយកចិត្តទុកដាក់ទៅលើចម្លើយសារភាពរបស់អ្នកទោសទាំងនោះទេ? ចម្លើយ: បក្សកុម្មុយនិស្ដកម្ពុជាមិនចាត់ទុកថាចម្លើយសារភាពនីមួយៗអាចយកជាការបាន ១០០% នោះទេ។ បក្សអានចម្លើយសារភាពមួយចប់ ហើយកំណត់អំពីភាពពិតនៃចម្លើយសារភាពនីមួយៗ និងធ្វើការវាយតម្លៃដោយឈរលើទស្សនៈផ្ទាល់ខ្លួន ចំណុចនេះពិត ចំណុចនេះមិនពិត ចំណុចនេះនិយាយពន្លើស”។ សំណួរ: ដូច្នេះតើមានប្រយោជន៍អ្វីក្នុងការចង់បានចម្លើយសារភាពពីអ្នកទោសនោះ? ចម្លើយ: ខ្ញុំយល់ច្បាស់ណាស់ថាចម្លើយសារភាពទាំងនោះគ្មានលក្ខណៈពិតប្រាកដទេ។ មានចម្លើយតិចណាស់ដែលអាចយកជាការបាន (...) ប៉ុន្តែអ្វីដែលសំខាន់នោះគឺត្រូវតែធ្វើយ៉ាងណាឲ្យបានចម្លើយសារភាព ហើយគេមិនសួរនាំខ្ញុំថាតើចម្លើយនោះពិតឬមិនពិតនោះទេ”។[4]

---

[3] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្ដុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ *ឯកសារតុលាការ D130/8* កថាខណ្ឌទី២៨

[4] បទសម្ភាសន៍របស់ ឌុច ជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៩ *ឯកសារតុលាការ D9/16, ERN 147873* - ទោះជាយ៉ាងណាក៏ដោយ ការដកស្រង់ពាក្យសម្ដីនេះមិនបង្កើតបានជាការទទួលស្គាល់ពីសំណាក់ជនត្រូវចោទ ចំពោះសេក្ដីប្រកាសដែលបានធ្វើនោះទេ។ម្យ៉ាងទៀត ក្រុមការពារក្ដីសូមរក្សាសិទ្ធិធ្វើ [បណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្ដុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម]

5. ម្យ៉ាងទៀត ពិរុទ្ធភាពនៃជនក្បត់ពីអតីតកាលអាចត្រូវបានរកឃើញដោយពុំចាំបាច់មានឯកសារអ្វីទាំងអស់ ទោះបីជាឯកសារទាំងនោះប្រឡាក់ជិតដាមទៅដោយឈាម ហើយដែលឈាមគឺជាមូលហេតុ និងជាលទ្ធផលនៃការកសាងឯកសារទាំងនោះក៏ដោយ។ ដូច្នេះឯកសារទាំងនោះគ្មានសារៈសំខាន់អ្វីឡើយ។

**ក្នុងគលៈទេសៈនេះ ក្រុមមេធាវីការពារក្ដីគាំទ្រ**

6. ជាមុន លើរាល់យោបល់ទាំងអស់ដោយគ្មានលក្ខខណ្ឌនៃសារណាបណ្ដឹងឧទ្ធរណ៍ របស់ក្រុមមេធាវីការពារក្ដីលោកស្រី អៀង ធីរិទ្ធិ ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត។

**ជាទីបញ្ចប់ និងដោយសម្អាងលើហេតុផលទាំងនេះ**

7. សហមេធាវីការពារក្ដីសូមស្នើដល់ចៅក្រមនៃអង្គបុរេជំនុំជម្រះមេត្តាទទួលយកនូវបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដី និងដោយមិនរារែកក្នុងការៈ
   - **បដិសេធ និងទុកជាមោឃៈ**នូវដីការបស់សហចៅក្រមស៊ើបអង្កេត
   - **បង្គាប់**ឲ្យមានការដកចេញពីនីតិវិធីនូវភស្តុតាងដែលត្រូវបានហាមឃាត់

**រក្សាសិទ្ធិកែប្រែគ្រប់បែបយ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | **មេធាវី ស សូវាន**<br>មេធាវី **Jacques VERGÈS** | ភ្នំពេញ<br>ប៉ារីស |  |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

ការបដិសេធគ្រប់ពេលវេលានូវភាពអាចទទួលយកបាន និង/ឬ មូលកភាពនៃការដកស្រង់ពាក្យសម្ដីនេះថាជាធាតុនៃភស្តុតាង ហើយការបដិសេធនេះគឺនៅគ្រប់ដំណាក់កាលនៃនីតិវិធី។